ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៧-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៧៥ ស្តីពី ការតែងតាំងលោក ហ៊ុន នី ជា ឧកញ៉ា ៥៦៣៩

១៧-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៧៦ ស្តីពី ការតែងតាំង ជាទីប្រឹក្សា និង ជំនួយការសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានរដ្ឋសភា នីតិកាលទី ៣ ចំនួន ០៥ រូប ៥៦៤០

១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៧៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ១៣ រូប នៃសហព័ន្ធនារីវៀតណាម ៥៦៤១

១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៨៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ នៃក្រសួង-ស្ថាប័នផ្សេងៗ ចំនួន ៥០ រូប ៥៦៤២


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២៧-៧-២០១២ -អនុក្រឹត្យលេខ ១១០ អនក្រ.បក ស្តីពី ការបង្កើតនាយកដ្ឋាននីតិកម្ម នៃក្រសួងសុខាភិបាល ៥៦៤៤

០១-៨-២០១២ -អនុក្រឹត្យលេខ ១១១ អនក្រ.បក ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈស្ថាបត្យករកម្ពុជា ៥៦៤៧

០១-៨-២០១២ -អនុក្រឹត្យលេខ ១១២ អនក្រ.បក ស្តីពី ការបង្កើតនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី នៃក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ៥៦៥៤

០១-៨-២០១២ -អនុក្រឹត្យលេខ ១១៣ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៥៦៥៧

០២-៨-២០១២ -អនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៥៦៥៩

២៥-៧-២០១២ -អនុក្រឹត្យលេខ ៨៩២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៦៦១

២៥-៧-២០១២ -អនុក្រឹត្យលេខ ៨៩៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៦៦២

២៥-៧-២០១២ -អនុក្រឹត្យលេខ ៨៩៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៦៦៣

២៥-៧-២០១២ -អនុក្រឹត្យលេខ ៨៩៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៦៦៤

២៥-៧-២០១២ -អនុក្រឹត្យលេខ ៨៩៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៦៦៥

២៥-៧-២០១២ -អនុក្រឹត្យលេខ ៨៩៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៦៦៦

២៥-៧-២០១២ -អនុក្រឹត្យលេខ ៨៩៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៦៦៧

២៧-៧-២០១២ -អនុក្រឹត្យលេខ ៨៩៩ អនក្រ.តត ស្តីពី ការតែងតាំងក្រុមប្រឹក្សាភិបាល នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី ៥ ៥៦៦៨

២៧-៧-២០១២ -អនុក្រឹត្យលេខ ៩០០ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥៦៧០

៣១-៧-២០១២ -អនុក្រឹត្យលេខ ៩០១ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ ៥៦៧១

០១-៨-២០១២ -អនុក្រឹត្យលេខ ៩០២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៦៧៣

០២-៨-២០១២ -អនុក្រឹត្យលេខ ៩០៣ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៥៦៧៤

០២-៨-២០១២ -អនុក្រឹត្យលេខ ៩០៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៦៧៥

០២-៨-២០១២ -អនុក្រឹត្យលេខ ៩០៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៦៨៤

០២-៨-២០១២ -អនុក្រឹត្យលេខ ៩០៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៦៨៥

០២-៨-២០១២ -អនុក្រឹត្យលេខ ៩០៧ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៥៦៨៧

០២-៨-២០១២ -អនុក្រឹត្យលេខ ៩០៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៦៨៨

០២-៨-២០១២ -អនុក្រឹត្យលេខ ៩០៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៦៨៩

០២-៨-២០១២ -អនុក្រឹត្យលេខ ៩១០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៦៩០

០២-៨-២០១២ -អនុក្រឹត្យលេខ ៩១១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៦៩២

០២-៨-២០១២ -អនុក្រឹត្យលេខ ៩១២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៦៩៣

០២-៨-២០១២ -អនុក្រឹត្យលេខ ៩១៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៦៩៤

០២-៨-២០១២ -អនុក្រឹត្យលេខ ៩១៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៦៩៥

០២-៨-២០១២ -អនុក្រឹត្យលេខ ៩១៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៦៩៦


## III~ការងារបណ្តាក្រសួង

## ទីស្តីការក្រសួងមន្ត្រីក្រសួងពាណិជ្ជកម្ម


១១-៤-២០១១ -លិខិតបញ្ជាក់លេខ ២០៤១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីន គួន អ៊ិនជាសស្ទ្រី (ខេមបូឌា)** ៥៦៩៨

១១-៤-២០១១ -លិខិតបញ្ជាក់លេខ ២០៤៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូនីត ម៉ាស គ្រុឌីង** ៥៧០០

១១-៤-២០១១ -លិខិតបញ្ជាក់លេខ ២០៤៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេម-ទៀក រ៉ូល ឌីវេឡុបមេន ខមភេនី ៥៧០២

១២-៤-២០១១ -លិខិតបញ្ជាក់លេខ ២០៤៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន មេគង្គ អេស៊ាន អ៊ិនធើប្រាយ ប្រឌើរហ្វីង ៥៧០៤

១២-៤-២០១១ -លិខិតបញ្ជាក់លេខ ២០៤៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន បេស ហូម (ខេមបូឌា) គ្រុប ៥៧០៦

១២-៤-២០១១ -លិខិតបញ្ជាក់លេខ ២០៥០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន 2 ឡេន អិចប្រេស ឃ្លារេនស៍ ៥៧០៨

១២-៤-២០១១ -លិខិតបញ្ជាក់លេខ ២០៥២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេទើប្រ្គីន ខិនសតធៀម ៥៧១០

១២-៤-២០១១ -លិខិតបញ្ជាក់លេខ ២០៥៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ភីធី ស៊ូរិយា គ្រុប ខូ អិលធីឌី ៥៧១២

១២-៤-២០១១ -លិខិតបញ្ជាក់លេខ ២០៦៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន មេគង្គ អាប្រ្គោ គ្រេដ (ខេមបូឌា) ៥៧១៤

១២-៤-២០១១ -លិខិតបញ្ជាក់លេខ ២០៦៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អាយ ធី ឌី ទើលស៍ ខូ អិលធីឌី ៥៧១៦

# ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**តែងតាំង**

**លោក ហ្វុង ទី**

**ជា**

**ឧកញ៉ា**

៣៧.១២០៧.៦៨៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៦៧១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងជាទីប្រឹក្សា និងជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ ចំនួន ០៥ រូប ដូចមានរាយនាមខាងក្រោម :

ក- **ទីប្រឹក្សា** ចំនួន ០៤ រូប :

១- ឯកឧត្តម **ខៀវ ពិសិដ្ឋ** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

២- ឯកឧត្តម **ម៉ៅ ធនិន** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៣- ឯកឧត្តម **ជៀម ប៊ុនណារិទ្ធ** មានឋានៈស្មើ **រដ្ឋលេខាធិការ**

៤- ឯកឧត្តម **គួច ស៊ីផាន់ណាល់** មានឋានៈស្មើ **រដ្ឋលេខាធិការ**

ខ- **ជំនួយការ** ចំនួន ០១ រូប :

១- ឯកឧត្តម **ហោ គ្រៃ** មានឋានៈស្មើ **អគ្គនាយក**

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧-១២០៧-៦៨៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១២

លេខៈ ៦៧០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែកក្កដា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន១៣រូប នៃសហព័ន្ធនារីវៀតណាម មានគុណបំណាច់ក្នុងការជួយ
ឧបត្ថម្ភថវិកាសម្រាប់កសាងអគារសិក្សា និងសមិទ្ធផលនានាជាច្រើនលើគ្រប់វិស័យ កន្លងមក

ដូច

**ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

១- លោកជំទាវ ធឿង មីហ័រ TRUONG MY HOA
២- លោកជំទាវ ហាធី ឃៀត HA THI KHIET
៣- លោកជំទាវ វ៉ូ ធីថាំង VO THI THANG
៤- លោកជំទាវ ង្វៀន ធីថាញ់ហ័រ NGUYEN THI THANH HOA
៥- លោកស្រី ង្វៀន ធីហ័រឡេ NGUYEN THI HOA LE
៦- លោក ត្រឹន ថាញ់ឡុង TRAN THANH LONG
៧- លោកស្រី ង្វៀន យុង NGUYEN DUNG
៨- លោកស្រី ង្វៀន ធីង៉ុកហ្វឿង NGUYEN THI NGOC PHUONG
៩- លោកស្រី ឌូ ធីហ្វីន ĐO THI PHIN

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

១- លោកស្រី ង្វៀន វៀតនី NGUYEN VIET NU
២- លោកស្រី ប៊ុយ ធីគីមក្វេ BUI THI KIM QUE
៣- ព្រះតេជគុណ ធីច មិញហ្វូ Venerable THICH MINH PHU
៤- វេជ្ជបណ្ឌិត ង្វៀន មិញខាយ Doctor NGUYEN MINH KHAI

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពនល.១២០៧.៦៤៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

លេខៈ ៦៦៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃ[illegible] ៥ ខែ កក្កដា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៩៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

មន្ត្រីរាជការ នៃក្រសួង-ស្ថាប័នផ្សេងៗ ចំនួន ៥០ រូប ដែលបានខិតខំបំពេញភារកិច្ច
និងមានទំនាក់ទំនងល្អ ជាមួយក្រសួងព្រះបរមរាជវាំង ក្នុងការបំរើជាតិ សាសនា ព្រះមហាក្សត្រ

**នូវ**

**ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- ឯកឧត្តម សៀង សុខឃុនធី
២- ឯកឧត្តម វង្ស ប៊ុនឥន្ទ្រាចុច
៣- លោកជំទាវ ស៊ី ដេហ៊ីន
៤- លោកជំទាវ សុខ ស៊ីថន
៥- លោក អន នាង

**ខ- គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :**

- ឧត្តមសេនីយ៍ ឆាយ ប៊ុណ្ណា

**គ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

- ឧត្តមសេនីយ៍ ជឹម សារឿន

**ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១- លោកជំទាវ ម៉ាន់ ម៉ារ៉ា
២- លោកជំទាវ ជូ ញូ ប៊ុនសម
៣- ឯកឧត្តម គីម សទ្វាត
៤- ឧត្តមសេនីយ៍ ឌឹម សារឿន
៥- លោក ជុប មុន្នី
៦- លោក ម៉ី សំបូរ
៧- លោក ឌិន សុខឃួន
៨- លោក សាម ប៊ុនហេង

**ង- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

- លោក មិន សុផេត

**ច- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :**

- លោក ស៊ុន គីមលី

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

ឆ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- លោក ឬទ្ធី សុគន្ធារិទ្ធ
២- លោក ខៀវ ប៊ុនថា
៣- កញ្ញា ចៅ សេដ្ឋចាន់លីដា
៤- លោក យូ ឫទ្ធី
៥- លោក ម៉ៅ នរិទ្ធ
៦- លោកស្រី យឹម ដារីយ៉ា
៧- លោក ម៉ា សុជាតិ

ជ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- លោកវេជ្ជបណ្ឌិត នាង ភារិទ្ធ
២- លោក ទេព សម្បត្តិ
៣- លោក សាន សុចិដា
៤- លោក មុំ រូន
៥- លោក បេ គីមឡាយ
៦- លោក អាង ណាត់
៧- លោក ជា ចណ្ឌា
៨- លោក គង ធីរៈ

ឈ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

- លោក ទឹម ចាន់ណារិទ្ធ

ញ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១- លោកវេជ្ជបណ្ឌិត តាំង សុផល
២- លោកស្រី កែវ ម៉ានី
៣- លោក ឧន់ ពៅ
៤- លោកស្រី ចៅ សេដ្ឋាមុនី
៥- លោក សូ សុជាតិ
៦- លោក ហុក ចិចិត្រ
៧- លោក មៀច សំអាត
៨- អ្នកស្រី សារិត សុខផល
៩- លោក ស៊ិន ចំរើន
១០- លោក កែវ សារីន
១១- អ្នកស្រី ជីវ សុចណ្ណាធី
១២- លោក ហាត់ សុភាណា
១៣- អ្នកស្រី ស ចិន្តា
១៤- អ្នកស្រី អ៊ុំ រ៉ាធី
១៥- លោក សុខ ណោន
១៦- លោក អៀង សុផល
១៧- អ្នកស្រី ប្រាជ្ញ ចាន់ណារី

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]. ១២០៣៣.៦៤៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

លេខៈ ៦៦៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ .ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកទំនាក់ទំនងរាជរដ្ឋាភិបាល
សយ សុខា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋាននីតិកម្មនៃក្រសួងសុខាភិបាល

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតនាយកដ្ឋាននីតិកម្មចំណុះអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ដើម្បីបំពេញបន្ថែមអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល។

**មាត្រា ២.-**

នាយកដ្ឋាននីតិកម្មមានតួនាទីនិងភារកិច្ចដូចតទៅ៖

- ជាសេនាធិការរបស់ក្រសួងសុខាភិបាល ក្នុងកិច្ចការនីតិកម្ម
- កសាង រៀបចំ និងតាក់តែងសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយផ្សេងៗទាក់ទងនឹងវិស័យសុខាភិបាល ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- ពិនិត្យ ផ្តល់យោបល់ និងកែសម្រួលសេចក្តីព្រាងច្បាប់ អត្ថបទច្បាប់ លិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងសុខាភិបាល
- បណ្តុះបណ្តាលនិងផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយជាធរមានទាក់ទងនឹងវិស័យសុខាភិបាល
- ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងវិស័យសុខាភិបាល
- សហការជាមួយអង្គភាពពាក់ព័ន្ធ ក្នុងការអង្កេតនូវរាល់ការអនុវត្តច្បាប់ទាក់ទងនឹងវិស័យសុខាភិបាល
- រៀបចំសំណុំឯកសារក្នុងកិច្ចដំណើរការដោះស្រាយវិវាទដែលពាក់ព័ន្ធនឹងវិស័យសុខាភិបាលតាមផ្លូវច្បាប់និងនីតិវិធីទៅតុលាការដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- គ្រប់គ្រងបណ្ណាល័យរបស់ក្រសួងនិងធ្វើការចែកផ្សាយសៀវភៅរាជកិច្ច
- ចងក្រងនិងតម្កល់ឯកសារច្បាប់ លិខិតបទដ្ឋានគតិយុត្តទាំងឡាយ ដែលពាក់ព័ន្ធនឹងវិស័យសុខាភិបាល
- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួងសុខាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំក្រសួងសុខាភិបាលប្រគល់ជូន។

**មាត្រា ៣.-**

នាយកដ្ឋាននីតិកម្មដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនតាមការចាំបាច់។

រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យដែលចំណុះនាយកដ្ឋាននីតិកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ដើម្បីស្នើសុំចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**វេជ្ជបណ្ឌិត ម៉ម ប៊ុនហេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១១១ .អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១១/១១២៤ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា ដែលសរសេរកាត់ថា "អគ្គលេខាធិការដ្ឋាន **គ.ស.ក.**"។

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន គ.ស.ក.

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន **គ.ស.ក.** មានតួនាទីជាអង្គភាពប្រតិបត្តិរបស់ **គ.ស.ក.**។

អគ្គលេខាធិការដ្ឋាន **គ.ស.ក.** ត្រូវអនុវត្តភារកិច្ចតាមខ្លឹមសារមាត្រា១១នៃព្រះរាជក្រឹត្យលេខ នស/រកត/១២១១/១១២៤ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន **គ.ស.ក.** ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់។

អគ្គលេខាធិការរងបំពេញភារកិច្ចតាមសេចក្តីសម្រេចស្តីពីការបែងចែកភារកិច្ចរបស់អគ្គលេខាធិការ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន **គ.ស.ក.** មានរចនាសម្ព័ន្ធដូចតទៅ៖

- ផ្នែករដ្ឋបាល បុគ្គលិក ផែនការ និងហិរញ្ញវត្ថុ
- ផ្នែកអប់រំនិងបណ្តុះបណ្តាល
- ផ្នែកទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការ
- ផ្នែកចុះបញ្ជីនិងគុណវុឌ្ឍិ
- ផ្នែកនីតិកម្មនិងដោះស្រាយវិវាទ
- ផ្នែកបច្ចេកទេសនិងស្រាវជ្រាវ
- ផ្នែកផ្សព្វផ្សាយនិងព័ត៌មានវិទ្យា។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ក.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

អគ្គលេខាធិការដ្ឋាន **គ.ស.ក.** អាចលើកសំណើកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ក.** តាមការចាំបាច់។

**មាត្រា ៥.-**

ផ្នែកនីមួយៗដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

ប្រធានផ្នែកមានឋានៈស្មើប្រធាននាយកដ្ឋាននិងអនុប្រធានផ្នែកមានឋានៈស្មើអនុប្រធាននាយកដ្ឋាន។

ផ្នែកនីមួយៗមានការិយាល័យមួយចំនួនតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែកនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាប្រធានក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា។

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋាន **គ.ស.ភ.** មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌមុខងារសាធារណៈ។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន **គ.ស.ភ.** អាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាដើម្បីជួយបំពេញការងារ។ អគ្គលេខាធិការដ្ឋាន **គ.ស.ភ.** អាចទទួលជំនួយឧបត្ថម្ភផ្សេងៗពីអង្គការជាតិនិងអន្តរជាតិ និងពីដៃគូអភិវឌ្ឍ។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាន **គ.ស.ភ.** អាចមានទីប្រឹក្សានិងជំនួយការជាតិនិងអន្តរជាតិមួយចំនួនតាមការចាំបាច់ដែលត្រូវបានយល់ព្រមនិងតែងតាំងដោយប្រធានក្រុមប្រឹក្សា **គ.ស.ភ.**។

អគ្គលេខាធិការដ្ឋាន **គ.ស.ភ.** មានសិទ្ធិប្រើត្រារបស់ **គ.ស.ភ.** ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

## ជំពូកទី៤
## ភារកិច្ចរបស់ផ្នែកនីមួយៗ

**មាត្រា ៨.-**

ផ្នែករដ្ឋបាល បុគ្គលិក ផែនការ និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ៖

- រៀបចំយុទ្ធសាស្ត្រ ផែនការ និងសកម្មភាពការងាររបស់ **គ.ស.ភ.**
- គ្រប់គ្រងការងាររដ្ឋបាលនិងមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន **គ.ស.ភ.**
- គ្រប់គ្រងថវិកានិងធ្វើរបាយការណ៍អំពីស្ថានភាពចំណូល ចំណាយរបស់**គ.ស.ភ.**
- រៀបចំកិច្ចការហិរញ្ញវត្ថុ គម្រោងថវិកាប្រចាំឆ្នាំ និងផែនការឆ្នាំបន្តរបស់ **គ.ស.ភ.**
- ថែរក្សា ទុកដាក់ឯកសារ បញ្ជីសារពើភណ្ឌ និងទ្រព្យសម្បត្តិរបស់ **គ.ស.ភ.**
- រៀបចំមហាសន្និបាតនិងកិច្ចប្រជុំផ្សេងៗរបស់ **គ.ស.ភ** ដោយសហការជាមួយផ្នែកផ្សេងៗ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងាររបស់ **គ.ស.ភ.**
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ៩.-**

**ផ្នែកអប់រំនិងបណ្តុះបណ្តាល** មានភារកិច្ចដូចតទៅ៖

- រៀបចំយុទ្ធសាស្ត្រ ផែនការ និងសកម្មភាពការងារអប់រំនិងបណ្តុះបណ្តាល
- រៀបចំការបណ្តុះបណ្តាលបំពេញបន្ថែមសម្រាប់ស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ភ.**
- រៀបចំការបណ្តុះបណ្តាលបន្តសម្រាប់ស្ថាបត្យករ **គ.ស.ភ.** ឲ្យមានគុណភាពស្របតាមការវិវត្តរបស់បច្ចេកវិទ្យា សង្គម សេដ្ឋកិច្ច វប្បធម៌ បរិស្ថាន និងលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈស្ថាបត្យកម្ម ដើម្បីធ្វើសមាហរណកម្មក្នុងតំបន់អាស៊ាននិងអន្តរជាតិតាមគោលការណ៍នៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើសេវាកម្មស្ថាបត្យកម្មក្នុងក្របខ័ណ្ឌអាស៊ាននិងអន្តរជាតិ
- រៀបចំសិក្ខាសាលា វគ្គបំប៉នខ្លីៗទៅតាមមុខជំនាញដែលជាតម្រូវការរបស់សង្គម

- រួមចំណែកក្នុងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈស្ថាបត្យកម្ម
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារអប់រំនិងបណ្តុះបណ្តាល
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ១០.-**

**ផ្នែកទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការ** មានភារកិច្ចដូចតទៅ៖

- រៀបចំយុទ្ធសាស្ត្រ ផែនការ និងសកម្មភាពការងារទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការ
- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា គ្រឹះស្ថានឧត្តមសិក្សា និងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីចូលរួមកំណត់កម្មវិធីសិក្សា វគ្គបំប៉នជំនាញ និងការអប់រំក្រោយឧត្តមសិក្សាផ្នែកជំនាញស្ថាបត្យកម្ម
- ធ្វើទំនាក់ទំនងនិងសហប្រតិបត្តិការជាមួយស្ថាប័នគ្រប់គ្រងវិជ្ជាជីវៈជាតិនិងអន្តរជាតិ ស្ថាប័ន ឬអង្គការ ដែលធ្វើការសិក្សាស្រាវជ្រាវផ្នែកស្ថាបត្យកម្មក្នុងនិងក្រៅប្រទេស វិស័យឯកជន និងសង្គមស៊ីវិលនានា ដើម្បីលើកកម្ពស់ចំណេះដឹងនិងគុណភាពនៃស្ថាបត្យករកម្ពុជា
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ១១.-**

**ផ្នែកចុះបញ្ជីនិងគុណវុឌ្ឍិ** មានភារកិច្ចដូចតទៅ៖

- រៀបចំយុទ្ធសាស្ត្រ ផែនការ និងសកម្មភាពការងារចុះបញ្ជីនិងគុណវុឌ្ឍិ
- ទទួលចុះបញ្ជីស្ថាបត្យករកម្ពុជានិងបរទេស
- ចងក្រងទិន្នន័យស្ថាបត្យករទូទាំងប្រទេស
- តាមដាន ត្រួតពិនិត្យសកម្មភាពប្រកបវិជ្ជាជីវៈរបស់ស្ថាបត្យករកម្ពុជានិងបរទេសដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា
- រៀបចំឯកសារវាយតម្លៃបេក្ខភាពស្ថាបត្យករចុះបញ្ជីដើម្បីឲ្យក្លាយទៅជាស្ថាបត្យករ **គ.ស.ក.** ដើម្បីដាក់ជូនគណៈកម្មការវាយតម្លៃពិនិត្យសម្រេច
- រៀបចំឯកសារវាយតម្លៃលើបេក្ខភាពស្ថាបត្យករ **គ.ស.ក.** ដើម្បីបំពេញលក្ខខណ្ឌជាស្ថាបត្យករអាស៊ាន សម្រាប់ដាក់ជូនគណៈកម្មការវាយតម្លៃពិនិត្យសម្រេច។ គណៈកម្មការវាយតម្លៃត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សា **គ.ស.ក.**
- រៀបចំបញ្ជីឈ្មោះស្ថាបត្យករដែលបានបញ្ចប់ការសិក្សាតាមគ្រឹះស្ថានបណ្តុះបណ្តាលស្ថាបត្យកម្មនានា
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារចុះបញ្ជីនិងគុណវុឌ្ឍិ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ១២.-**

**ផ្នែកនីតិកម្មនិងដោះស្រាយវិវាទ** មានភារកិច្ចដូចតទៅ៖

- រៀបចំយុទ្ធសាស្ត្រ ផែនការ និងសកម្មភាពការងារនីតិកម្មនិងដោះស្រាយវិវាទ
- រៀបចំបទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌ស្ថាបត្យករ និងលិខិតបទដ្ឋានគតិយុត្ត នានាដែលពាក់ព័ន្ធនឹងវិស័យស្ថាបត្យកម្ម
- ជួយក្រុមប្រឹក្សាវិន័យក្នុងការទទួលបណ្តឹងតវ៉ាផ្សេងៗពាក់ព័ន្ធនឹងស្ថាបត្យករ ដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** និងដោះស្រាយវិវាទផ្សេងៗដែលពាក់ព័ន្ធ នឹងវិស័យស្ថាបត្យកម្ម
- រៀបចំឯកសារសម្រាប់ដាក់ទណ្ឌកម្មខាងវិន័យដល់ស្ថាបត្យករដែលបាន ចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** ណាដែលបានប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌ ស្ថាបត្យករ
- ការពារភាពស្របច្បាប់នៃការប្រកបវិជ្ជាជីវៈស្ថាបត្យកម្មរបស់ស្ថាបត្យករដែល បានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.**
- ពិនិត្យ សិក្សាស្រាវជ្រាវអនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ ច្បាប់ និងលិខិត បទដ្ឋានគតិយុត្តទាំងឡាយដែលទាក់ទងនឹងវិស័យស្ថាបត្យកម្ម
- ចូលរួមរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យ ស្ថាបត្យកម្មតាមការអញ្ជើញរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ផ្តល់ប្រឹក្សាផ្នែកនីតិកម្មលើវិស័យស្ថាបត្យកម្ម
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារនីតិកម្មនិងដោះស្រាយវិវាទ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ១៣.-**

**ផ្នែកបច្ចេកទេសនិងស្រាវជ្រាវ** មានភារកិច្ចដូចតទៅ៖

- រៀបចំយុទ្ធសាស្ត្រ ផែនការ និងសកម្មភាពការងារបច្ចេកទេសនិងស្រាវជ្រាវ
- រៀបចំនិងចូលរួមក្នុងការសិក្សាស្រាវជ្រាវវិស័យស្ថាបត្យកម្មជាតិនិងអន្តរជាតិ ដើម្បីលើកកម្ពស់ស្ថាបត្យកម្មដែលមានអត្តសញ្ញាណជាតិ
- រៀបចំនិងចូលរួមការសិក្សាស្រាវជ្រាវ ការរកឃើញ និងបច្ចេកវិទ្យាថ្មីៗក្នុង និងក្រៅប្រទេសលើវិស័យស្ថាបត្យកម្ម ដើម្បីនាំយកមកប្រើប្រាស់និងផ្តល់ ជូនស្ថាបត្យករកម្ពុជានិងបរទេស
- ចូលរួមរៀបចំពិព័រណ៍និងការប្រកួតប្រជែងស្នាដៃស្ថាបត្យកម្ម ពិសេស ស្ថាបត្យកម្ម ដែលមានលក្ខណៈជាតិ
- ផ្តល់ប្រឹក្សាបច្ចេកទេសលើវិស័យស្ថាបត្យកម្ម
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារបច្ចេកទេសនិងស្រាវជ្រាវ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ១៤.-**

**ផ្នែកផ្សព្វផ្សាយនិងព័ត៌មានវិទ្យា** មានភារកិច្ចដូចតទៅ៖

- រៀបចំយុទ្ធសាស្ត្រ ផែនការ និងសកម្មភាពការងារផ្សព្វផ្សាយនិងព័ត៌មានវិទ្យា

- ផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសដែលពាក់ព័ន្ធនឹងវិស័យស្ថាបត្យកម្ម
- សិក្សា ស្រាវជ្រាវ ចងក្រង បោះពុម្ព និងផ្សព្វផ្សាយព័ត៌មាននិងទិន្នន័យដែលពាក់ព័ន្ធនឹងវិស័យស្ថាបត្យកម្មជាតិនិងអន្តរជាតិ
- ផ្សព្វផ្សាយស្នាដៃស្ថាបត្យកម្មដែលមានអត្តសញ្ញាណជាតិ
- ផ្សព្វផ្សាយការរកឃើញនិងបច្ចេកវិទ្យាថ្មីៗដែលទាក់ទងនឹងវិស័យស្ថាបត្យកម្ម
- រៀបចំគេហទំព័ររបស់ **គ.ស.ភ.**
- រៀបចំនិងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យារបស់ **គ.ស.ភ.**
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារផ្សព្វផ្សាយនិងព័ត៌មាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានក្រុមប្រឹក្សា **គ.ស.ភ.** រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មី៣ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា

## អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី ចំណុះអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីបំពេញបន្ថែមអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា ២.-**

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី មានតួនាទីនិងភារកិច្ច ដូចតទៅ៖

- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍បម្រើឱ្យប្រព័ន្ធចុះបញ្ជីដីធ្លី
- គ្រប់គ្រងការងារបច្ចេកវិទ្យាព័ត៌មានសុរិយោដី ការងារប្រព័ន្ធព័ត៌មានដីធ្លី ការងារថែរក្សាទិន្នន័យចុះបញ្ជីដីធ្លី និងផែនទីសុរិយោដី
- រៀបចំការបណ្តុះបណ្តាលផ្នែកប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ការងារសុរិយោដី និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ
- រៀបចំកំណត់លក្ខណៈបច្ចេកទេសនៃឧបករណ៍សម្ភារៈនិងកម្មវិធីព័ត៌មានវិទ្យា សម្រាប់បម្រើការងារសុរិយោដី
- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន និងដៃគូអន្តរជាតិ លើការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ។

**មាត្រា ៣.-**

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី ត្រូវដឹកនាំដោយប្រធានមួយរូបអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ៤.-**

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី មានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់។ តួនាទីនិងភារកិច្ចរបស់ការិយាល័យចំណុះនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។/.

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ឧសភា. ឆ្នាំ២០១២*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីស្នើសុំចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

***កន្លែងទទួល៖***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *គ្រប់សាលារាជធានី ខេត្ត*
- *ដូចមាត្រា៦*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន១២៨១លានរៀល(មួយពាន់ពីររយប៉ែតសិបមួយលានរៀលគត់) ពីជំពូក ០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក៦០(ការទិញ) ជូនក្រសួងមហាផ្ទៃ(ផ្នែកសន្តិសុខសាធារណៈ) សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទិញសម្លៀកបំពាក់ឧបករណ៍ការពារបាតុកម្មចំនួន ២ ០០០សម្រាប់។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ,ថ្ងៃទី ០២ ខែ៧ ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៩៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន៤ ០០០ ០០០ ០០០រៀល(បួនពាន់លានរៀលគត់) ពីជំពូក ០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦៥ (ឧបត្ថម្ភកធននិងជំនួយសង្គម) ជូនក្រសួងសុខាភិបាល សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីទូទាត់បុរេប្រទានដែលបានផ្តល់ជូនមន្ទីរពេទ្យគន្ធបុប្ផា សម្រាប់ចំណាយទប់ស្កាត់និងព្យាបាលការផ្ទុះឡើងនូវជម្ងឺឆ្លងទារកនិងកុមារឆ្នាំ២០១២។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ ៧ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៩៧ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា ១-** ត្រូវបានតែងតាំងលោក សុខ ស៊ុនលីន ជា អគ្គនាយករង នៃអគ្គនាយកដ្ឋានសាធារណការ ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ២-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុង មាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៨៩៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគម GENMAI KOSO Co., Ltd ប្រទេសជប៉ុន ដែលបានផ្តល់ថវិកាចំនួន ៤៩.២៩០,២០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់បន្ទប់ និងបង្គន់អនាម័យ ០៤បន្ទប់ ជូនដល់សាលាបឋមសិក្សាអធិបតី ស្ថិតនៅស្រុកពួក ខេត្តសៀមរាប ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៨១៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណ:រដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនកូរ៉េ ចំនួន០២រូប ដែលបានចំណាយថវិកាសរុបចំនួន ៣១៧.២៤០,៣០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន០៩ខ្នង មាន២៦បន្ទប់ ជូនដល់សាលារៀនចំនួន០៩ ស្ថិតនៅខេត្តរតនគីរី ដូចមានរាយនាមខាងក្រោម ៖

១-សម្តេចព្រះសង្ឃ Pomnyun Snim សប្បុរសជន

២-លោក Chul Sang Jung សប្បុរសជន

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណ:រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណ:អភិបាលខេត្តរតនគីរី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៩៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនវៀតណាម ចំនួន០៣រូប ដែលបានចំណាយថវិកាសរុបចំនួន ៩៥០.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអនុវិទ្យាល័យអន្តេវាសិកដ្ឋានសែនមនោរម្យ ស្ថិតនៅភូមិចំការតែ ឃុំស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក | Tran Xuan Hai | ប្រធានមន្ទីរផែនការ និងវិនិយោគខេត្តដាក់ណុង |
| ២-លោក | Ho Viet Dong | ប្រធានក្រុមហ៊ុន TNHHXD Thanh Cong |
| ៣-លោក | Ngein Goueng | នាយកគ្រប់គ្រងគម្រោងសាងសង់ ខេត្តដាក់ណុង |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគីរី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ៨៩៧-អនក្រ-បក**

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០២រូប ដែលបានផ្តល់ថវិកាក្នុងការទិញសម្ភារៈសិក្សាជាច្រើន ប្រើប្រាស់ក្នុងវិស័យអប់រំ ជូនដល់សាលាបឋមសិក្សាតាតៃ ស្ថិតនៅស្រុកកោះកុង ខេត្តកោះកុង ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ**

-លោក Paul Blanche-Horgan បានផ្តល់ថវិកាចំនួន ១៧.២០០ ដុល្លារអាមេរិក

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

-អ្នកស្រី Janet Magaret Newman បានផ្តល់ថវិកាចំនួន ៧.០០០ ដុល្លារអាមេរិក

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៩៣៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូន នាយទាហានជើងទឹកសហរដ្ឋអាមេរិក ដែលបានផ្តល់ថវិកាចំនួន ៧១២.៧១៥ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន០៣ខ្នង មាន១៣បន្ទប់ អណ្តូងទឹក០៣ បង្គន់អនាម័យ០៥ខ្នង មាន២២បន្ទប់ តុសិស្សចំនួន២៦០ តុគ្រូចំនួន១៩ កៅអីគ្រូចំនួន៣០ ក្តារខៀនចំនួន១៣ បំពាក់ឧបករណ៍សឡា ចំនួន៦ផ្ទាំង មានសម្ភារៈកំប្លេ អាងស្តុកទឹកចំនួន០៣ និងធុងដែកចំនួន៣ ជូនដល់វិទ្យាល័យសណ្តាន់ សាលាបឋមសិក្សាស្រែត្រែង២ និងសាលាបឋមសិក្សាចង្ក្រប ស្ថិតនៅខេត្តក្រចេះ ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៩៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០៣គ្រឿង ជូនអង្គការ ចំនួន០៣ ដែលបានផ្តល់ថវិកាសរុបចំនួន ៦០.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ជូនដល់សាលាបឋមសិក្សា ចំការកៅស៊ូ ស្ថិតនៅភូមិ១ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដូចមានរាយខាងក្រោម ៖

១-សមាគម International Volunteer University Student Association

២-អង្គការ IVUSA Cambodia Office

៣-ក្រុមអ្នកប្រមូលថវិការបស់អង្គការ IVUSA Fund-raising

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៩៥ .អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងក្រុមប្រឹក្សាភិបាល នៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី ៥

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការកែសំរួលអនុក្រឹត្យលេខ ៥២ អនក្រ.បក ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៦៦៤ អនក្រ.តត ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១២ ស្តីពីការតែងតាំងអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- យោងតាមសំណើរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## សម្រេច

**មាត្រា ១:** តែងតាំងក្រុមប្រឹក្សាភិបាលអាណត្តិទី៥ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ម៉េង សក្តិដារ៉ា | អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាប្រធាន |
| ២- លោក | ស៊ឹម ស៊ីថា | អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ជាសមាជិក |

| | | | |
|---|---|---|---|
